# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ
# សម្រាប់ក្រុមគ្រូបង្គោលថ្នាក់ជាតិ

## Training Manual on Food Security and Nutrition

*"In Context of Climate Change and Food Price Increasing"*




**រៀបចំដោយ:** អង្គភាពបណ្តុះបណ្តាល សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៃ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី

**ឧបត្ថម្ភដោយ:** អង្គការការីតាស កម្ពុជា


ខែធ្នូ ឆ្នាំ២០១៤

# សេចក្តីថ្លែងអំណរគុណ

សៀវភៅបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ក្រុមគ្រូបង្គោលថ្នាក់ជាតិនេះជាឯកសារលើកដំបូង ដែលបានផលិតឡើងនៅព្រះរាជាណាចក្រកម្ពុជា។ ការផលិតចេញជាសៀវភៅនេះឡើង គឺដោយសារមានសំណូមពរ និងតម្រូវការចាំបាច់ពីក្រុមគ្រូបង្គោលថ្នាក់ជាតិ សម្រាប់បណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ការកើតឡើងនូវសមិទ្ធផលដ៏មានសារសំខាន់នេះ គឺដោយសារការខិតខំរួមគ្នារវាងបណ្តាសមាជិកក្រុមគ្រូបង្គោលថ្នាក់ជាតិទាំងអស់ រួមនឹងមន្ត្រីជំនាញមកពីស្ថាប័នពាក់ព័ន្ធនានា ទាំងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបណ្តាអង្គការសង្គមស៊ីវិល ដែលរួមគ្នាប្រមែប្រមូល ចំណេះដឹង បទពិសោធន៍ មេរៀនល្អៗ លើការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ចងក្រងជាសៀវភៅនេះឡើង។ ម្យ៉ាងវិញទៀតប្រសិនបើគ្មានការឧបត្ថម្ភជាថវិកាក្នុងការរៀបចំនិងបោះពុម្ពពីសំណាក់អង្គការការីតាសកម្ពុជា (CARITAS Cambodia) ក៏សៀវភៅនេះមិនអាចកើតឡើងបានដែរ ។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាពិសេសអង្គភាពបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមគ្រូបង្គោលថ្នាក់ជាតិបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងអស់ រួមនឹងបណ្តាមន្ត្រីជំនាញមកពីអន្តរស្ថាប័នទាំងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមចំណែក ចែករំលែកចំណេះដឹង បទពិសោធន៍ និងមេរៀនល្អៗ ក្នុងការរៀបចំចងក្រងសៀវភៅដ៏មានសារសំខាន់នេះឡើង។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាពិសេសអង្គភាពបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះអង្គការការីតាសកម្ពុជា (CARITAS Cambodia) ដែលបានផ្តល់មន្ត្រីជំនាញចូលរួមរៀបចំ និងឧបត្ថម្ភថវិកាទាំងការរៀបចំ និងការបោះពុម្ព។

**អង្គភាពបណ្តុះបណ្តាល ស.ស.អ នៃ ក.ក.ជ**

# អារម្ភកថា

សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាបញ្ហាអន្តរវិស័យដ៏ស្មុគស្មាញមួយ ដែលទាមទារឲ្យមានការចូលរួមយ៉ាងសកម្មពីបណ្តាតួអង្គពាក់ព័ន្ធទាំងអស់ មិនត្រឹមតែក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ឬវិស័យឯកជនប៉ុណ្ណោះទេ ក៏ប៉ុន្តែប្រជាពលរដ្ឋ និងបុគ្គលម្នាក់ៗចាំបាច់ត្រូវមានការយល់ដឹង និងចូលរួមយ៉ាងសកម្ម ទើបកិច្ចអន្តរាគមន៍ដោះស្រាយកែលម្អស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទទួលបានលទ្ធផលល្អប្រសើរ។

ក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជាមួយនឹងការតាំងចិត្តក្នុងការសម្រេចឲ្យបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គ្រប់គ្រាន់នៅទូទាំងប្រទេស ដោយចាត់ទុកថាជាលក្ខខ័ណ្ឌមួយដ៏សំខាន់សម្រាប់ធានាឲ្យមាននូវការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចក្នុងកម្រិតមួយខ្ពស់ ភាពចំរុងចំរើន និងសមធម៌សម្រាប់ពលរដ្ឋកម្ពុជាគ្រប់រូប ជាមួយនឹងចក្ខុវិស័យរយៈពេលវែងគឺ “ **ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានលទ្ធភាព ផ្នែករូបវន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុន ក្នុងការទទួលបាននូវអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភគ្រប់ពេលវេលា ដើម្បីឱ្យស្របទៅនឹងសេចក្តីត្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់អាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់** ”។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់នៅក្នុងឱកាសបើកសិក្ខាសាលាជាតិលើកទី៤ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ កាលពីខែឧសភា ឆ្នាំ២០១២ ថា“ **ដំណោះស្រាយពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មិនត្រឹមតែជាការឆ្លើយតបទៅ នឹងគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញកន្លងមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការដោះស្រាយនូវទុក្ខលំបាក ការលើកស្ទួយកម្រិតជីវភាពរស់នៅ និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនទៀតផង** ”។

សេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនគួរឲ្យកត់សម្គាល់ បើទោះបីថាកម្ពុជាបានរងនូវឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចជាសកល និងគ្រោះមហន្តរាយធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ប៉ុន្តែកម្ពុជានៅរក្សាបានលំនឹងសេដ្ឋកិច្ចមួយយ៉ាងល្អប្រសើរ ធ្វើឲ្យជីវភាពប្រជាពលរដ្ឋទូទៅមានការរីកចំរើន។ ទន្ទឹមនឹងភាពជោគជ័យ និងការរីកចំរើនជាច្រើនវិស័យរបស់កម្ពុជា យើងសង្កេតឃើញថាបញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភនៅតែជាបញ្ហាចោទ ជាពិសេសទៅលើកុមារ និងស្ត្រី បើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់និងសកលលោកទាំងមូល។ តាមការអង្កេតសិក្សាស្រាវជ្រាវ កត្តាជីវភាព គឺជាបញ្ហាមួយ ប៉ុន្តែមានបញ្ហាជាច្រើនទៀតដែលធ្វើឲ្យកុមារ និងស្ត្រីនៅកម្ពុជាជួប

បញ្ហាអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភដូចជា៖ ការមិនយកចិត្តទុកដាក់លើការចិញ្ចឹមបីបាច់ថែរក្សាកុមារតូច កង្វះអនាម័យក្នុងការរស់នៅ ការរៀបចំអាហារមិនសមស្របតាមតម្រូវការរាងកាយជាដើម។ ការកើតឡើងបញ្ហាទាំងអស់នេះគឺ បណ្តាលមកពីការយល់ដឹងលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋយើងនៅមានកម្រិត។

សៀវភៅបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ក្រុមគ្រូបង្គោលថ្នាក់ជាតិ ពិតជាមានសារៈសំខាន់សម្រាប់ផ្តល់ឲ្យក្រុមគ្រូបង្គោលថ្នាក់ជាតិទាំងអស់ យកធ្វើជាមូលដ្ឋានក្នុងការបណ្តុះបណ្តាល ចែករំលែកចំណេះដឹង បទពិសោធន៍ មេរៀនល្អៗ និងការរៀបចំផែនការអភិវឌ្ឍន៍មូលដ្ឋាន ដោយដាក់បញ្ចូលកិច្ចអន្តរាគមន៍កែលម្អស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជូនដល់អ្នកពាក់ពន្ធ័ទាំងអស់ដែលជាអ្នកដឹកនាំ អ្នកធ្វើផែនការនៅតាមវិស័យ និងស្ថាប័នរបស់ខ្លួនតាមរយៈការបណ្តុះបណ្តាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ អង្គភាពបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងក្រុមគ្រូបង្គោលថ្នាក់ជាតិបណ្តុះបណ្តាលសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកសមាជិកានៃក្រុមគ្រូបង្គោលថ្នាក់ជាតិទាំងអស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលា ចំណេះដឹង និងបទពិសោធន៍ចូលរួមក្នុងការផ្តល់មតិយោបល់ កែលម្អសៀវភៅនេះឲ្យកាន់តែមានខ្លឹមសារ និងសារៈប្រយោជន៍ប្រសើរឡើងថែមទៀត។ជាមួយគ្នានេះខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គការការីតាសកម្ពុជា (CARITAS Cambodia) ដែលបានផ្តល់មន្ត្រីជំនាញ និងថវិកាក្នុងការរៀបចំ និងបោះពុម្ពសៀវភៅដ៏មានសារៈសំខាន់នេះ។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨

**អង្គភាពបណ្តុះបណ្តាល ស.ស.អ នៃ ក.ក.ជ**

**ប្រធាន**



**វ័ត្ត ទិរៈ**

# មាតិកា

**១.អារម្ភកថា**

**២.សមាសភាពក្រុមគ្រូបង្គោលថ្នាក់ជាតិ**

**៣.បញ្ជីអក្សរកាត់**

**៤.កម្មវិធីបើកវគ្គ**

៤.១.មតិស្វាគមន៍ និងបើកវគ្គ

៤.២.ការណែនាំពីសិក្ខាកាម គ្រូបង្គោល គោលបំណង របៀបធ្វើការងារ និងការរំពឹងទុករបស់សិក្ខាកាម

៤.៣.ការវាយតម្លៃសមត្ថភាពរបស់សិក្ខាកាមមុនពេលចាប់ផ្តើមវគ្គ

**៥.ទស្សនទាននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (ស.ស.អ)**

៥.១.និយមន័យនៃ ស.ស.អ

៥.២.ការបែងចែកលំដាក់ថ្នាក់ ស.ស.អ (ម៉ាក្រូ មេសូ និងមីក្រូ)

៥.៣.វិសាលភាពនៃ ស.ស.អ

៥.៤.ការស្តែងឱ្យឃើញពីលទ្ធផលអសន្តិសុខស្បៀង ឬសញ្ញាបញ្ហាអាហារូបត្ថម្ភ

៥.៥ ក្របខ័ណ្ឌទស្សនៈនៃមូលហេតុដែលបណ្តាលឲ្យមានកង្វះអាហារូបត្ថម្ភ

**៦.យន្តការ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងគោលនយោបាយនានា ពាក់ព័ន្ធនឹង ស.ស.អ (ទំនាក់ទំនងរវាង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការកាត់បន្ថយភាពក្រីក្រ)**

៦.១. យន្តការសម្របសម្រួលលើការងារ ស.ស.អ

៦.១.១.ក្រុមការងារបច្ចេកទេសគាំពារសង្គម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

៦.១.២.វេទិកាជាតិស្តីពីសន្តិសុខស្បៀង

៦.១.៣.ក្រុមការងារគ្រប់គ្រងព័ត៌មាន និងក្រុមវិភាគទិន្នន័យ ស.ស.អ

៦.១.៤.ក្រុមការងារប្រព័ន្ធព័ត៌មាន ស.ស.អ

៦.១.៥.ក្រុមគ្រូបង្គោលថ្នាក់ជាតិ

៦.១.៦.ចលនាភូមិមួយផលិតផលមួយ

៦.២.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផយអជ) ២០១៤-២០១៨

៦.៣.ក្របខ័ណ្ឌយុទ្ធសាស្ត្រ ស.ស.អ ២០០៨-២០១២

៦.៤.យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨

៦.៥.យុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភ ២០០៩-២០១៥

៦.៦ ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០

៦.៧.យុទ្ធសាស្ត្រកសិកម្ម និងទឹក

៦.៨.គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា

៦.៩.យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ២០១១-២០១៥
៦.១០. ទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងស.ស.អ
៦.១១. ទំនាក់ទំនងរវាងយេនឌ័រ និងស.ស.អ

## ៧.ការគ្រប់គ្រងវដ្តនៃគម្រោង

## ៨.ការវិភាគ និងវាយតម្លៃពីស្ថានភាព ស.ស.អ នៅក្នុងមូលដ្ឋាន ឬតំបន់

៨.១.ពិភាក្សាជាក្រុម និងបង្ហាញលទ្ធផលពីស្ថានភាព ស.ស.អ នៅក្នុងមូលដ្ឋាន ឬតំបន់
៨.២.ការបង្ហាញលទ្ធផលក្រុមពិភាក្សា

## ៩.សកម្មភាពដែលបាន និងកំពុងធ្វើក្នុងកិច្ចអន្តរាគមន៍ដើម្បីកែលម្អ ស.ស.អ នៅមូលដ្ឋាន ឬតំបន់

៩.១.ពិភាក្សាជាក្រុម និងបង្ហាញពីសកម្មភាពដែលបាន និងកំពុងធ្វើក្នុងកិច្ចអន្តរគមន៍ ដើម្បីកែលម្អ ស.ស.អ នៅមូលដ្ឋាន ឬតំបន់
៩.២. ការបង្ហាញលទ្ធផលក្រុមពិភាក្សា

## ១០.សូចនាកររបស់ ស.ស.អ

១០.១.ការបង្ហាញពីសូចនាករមួយចំនួនរបស់ ស.ស.អ (ភាពមានស្បៀង លទ្ធភាពទទួលបាន -ស្បៀង ការប្រើប្រាស់ និងការបឺតស្រូបស្បៀង និងស្ថេរភាពស្បៀង)

## ១១.ផែនការសកម្មភាពអាទិភាពដើម្បីអន្តរាគមន៍ កែលម្អ ស.ស.អ នៅក្នុងមូលដ្ឋាន ឬតំបន់

១១.១.ពិភាក្សាជាក្រុម និងបង្ហាញពីផែនការសកម្មភាពអាទិភាពដើម្បីអន្តរាគមន៍ កែលម្អ ស.ស.អ នៅក្នុងមូលដ្ឋាន ឬតំបន់

## ១២. ការដាក់បញ្ចូល និងការបញ្ជ្រាប ស.ស.អ ទៅក្នុងផែនការ និងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានឬតំបន់

១២.១.ការដាក់បញ្ចូល ស.ស.អ ទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន ឬតំបន់
១២.២.ការបង្ហាញអំពីវិធីសាស្ត្រសម្រាប់ធ្វើការបញ្ជ្រាប ស.ស.អ

## ១៣. ការគ្រប់គ្រងចំណេះដឹង និងព័ត៌មាន ស.ស.អ

១៣.១.ការបង្ហាញពីរបៀបមើលឬទទួលព័ត៌មាន ស.ស.អនៅលើគេហទំព័រប្រព័ន្ធព័ត៌មាន ស.ស.អ នៅកម្ពុជា

## ១៤.ការវាយតម្លៃវគ្គបណ្តុះបណ្តាល

១៤.១.ការវាយតម្លៃសមត្ថភាពរបស់សិក្ខាកាមក្រោយបញ្ចប់វគ្គ
១៤.២.ការវាយតម្លៃទូទៅនៃវគ្គ (ការរៀបចំ ឯកសារ ប្រធានបទ គ្រូបណ្តុះបណ្តាល...)

## ១៥.ពិធីបិទវគ្គ និងចែកវិញ្ញាបនបត្រ

## ១៦.ឧបសម្ព័ន្ធ

១៦.១.កម្មវិធីវគ្គបណ្ដុះបណ្ដាល

១៦.២.សន្ទានុក្រមស្ដីពីសន្តិសុខស្បៀង និងសន្តិសុខអាហារូបត្ថម្ភ

១៦.៣.បទបង្ហាស្ដីពីការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងយន្តការសម្របសម្រួល

១៦.៤.ការស្វែងឱ្យឃើញពីលទ្ធផលអសន្តិសុខស្បៀង ឬសញ្ញាបញ្ហាអាហារូបត្ថម្ភ

១៦.៥.បទបង្ហាញស្ដីពីការផ្សារភ្ជាប់រវាងស.ស.អ ទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន

១៦.៦.ឧបករណ៍សម្រាប់ធ្វើការបញ្ជ្រាបស.ស.អ

១៦.៧.បញ្ជីសំនួរតេស្តសាកល្បងមុនពេល និងក្រោយពេលវគ្គបណ្ដុះបណ្ដាល

១៦.៨.រូបភាពពាក់ព័ន្ធនឹងអាហារូបត្ថម្ភ